**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ: ០២៦ ដនស/ប្រក

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រកាសលេខ ១៩២ ប្រក.ដនស/អសណ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ និងប្រកាសលេខ ៧៥ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១២ ស្តីពីការបង្កើតនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានសុរិយោដីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ២៤៥ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១២០ អនក្រ.បក ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានសម្បទានដីសង្គមកិច្ចចំណុះអគ្គនាយកដ្ឋានលំនៅឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៤១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានកិច្ចការវិវាទដីធ្លីចំណុះអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ  ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ២៨៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់
- យោងប្រកាសលេខ ៧៥ប្រក/ជនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាសនិងក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់
- យោងប្រកាសលេខ ១៦៦ ប្រក.ជនស/អសណ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧ ស្តីពីការកែសំរួលប្រការ៧ និង ប្រការ១០ នៃប្រកាសលេខ ៧៥ប្រក/ជនស ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់
- យោងប្រកាសលេខ១៩២ ប្រក.ជនស/អសណ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់
- យោងប្រកាសលេខ០៣៥ ប្រក.ជនស/អសណ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៦ នៃប្រកាសលេខ១៩២ ប្រក.ជនស/អសណ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការមួយ._**

ប្រការ៦ថ្មី នៃប្រកាសលេខ ១៩២ ប្រក.ជនស/អសណ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគំរោងប្លង់ ត្រូវបានកែសម្រួលដូចតទៅ៖

**ប្រការ៦._ថ្មី(មួយ)**

១. វិញ្ញាបនបត្រសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈជាស្ថាបត្យករមាន ២(ពីរ)កម្រិតដូចខាងក្រោម៖

ក- វិញ្ញាបនបត្រសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម កម្រិត១ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈជា **ស្ថាបត្យករ គ.ស.ក** ដើម្បីអនុវត្តការងារសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម សម្រាប់សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ខ-វិញ្ញាបនបត្រសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម កម្រិត២ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈជា **ស្ថាបត្យករចុះបញ្ជី** ដើម្បីអនុវត្តការងារសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម សម្រាប់សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

២. វិញ្ញាបនបត្រសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈជាវិស្វករមាន ២(ពីរ)កម្រិតដូចខាងក្រោម៖

ក-វិញ្ញាបនបត្រសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់ កម្រិត១ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈជា **វិស្វករអាជីព** ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច៧(ប្រាំពីរ)ឆ្នាំ ដើម្បីអនុវត្តការងារសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់ សម្រាប់សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ខ-វិញ្ញាបនបត្រសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់ កម្រិត២ សម្រាប់ផ្តល់ជូន **វិស្វករអាជីព** ដើម្បីអនុវត្តការងារសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់ សម្រាប់សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

៣. វិញ្ញាបនបត្រសិក្សាគម្រោងប្លង់ប្រព័ន្ធមេកានិក សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈជា**វិស្វករអាជីព** ដើម្បីអនុវត្តការងារសិក្សាគម្រោងប្លង់ប្រព័ន្ធមេកានិក សម្រាប់សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៤. វិញ្ញាបនបត្រសិក្សាគម្រោងប្លង់ប្រព័ន្ធអគ្គិសនី សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈជាវិស្វករមាន ២(ពីរ)កម្រិតដូចខាងក្រោម៖

ក-វិញ្ញាបនបត្រសិក្សាគម្រោងប្លង់ប្រព័ន្ធអគ្គិសនី កម្រិត១សម្រាប់ផ្តល់ជូន **វិស្វករអាជីព** ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច៧ (ប្រាំពីរ)ឆ្នាំ ដើម្បីអនុវត្តការងារសិក្សាគម្រោងប្លង់ប្រព័ន្ធអគ្គិសនី សម្រាប់សំណង់លំនៅឋាន អគារសហកម្មសិទ្ធិ

និងអគារប្រើប្រាស់ចម្រុះ ជញ្ជាំងទប់ដី និងរបង ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ខ-វិញ្ញាបនបត្រសិក្សាគម្រោងប្លង់ប្រព័ន្ធអគ្គិសនី កម្រិត២ សម្រាប់ផ្តល់ជូន **វិស្វករអាជីព** ដើម្បីអនុវត្តការងារសិក្សាគម្រោងប្លង់ប្រព័ន្ធអគ្គិសនី សម្រាប់សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

៥. វិញ្ញាបនបត្រសិក្សាគម្រោងប្លង់ប្រព័ន្ធទឹក សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈជា**វិស្វករអាជីព** ដើម្បីអនុវត្តការងារសិក្សាគម្រោងប្លង់ប្រព័ន្ធទឹក សម្រាប់សំណង់គ្រប់ប្រភេទដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

បទពិសោធន៍ការងារក្នុងមុខជំនាញរបស់អ្នកវិជ្ជាជីវៈដែលបានបំពេញមុនកាលបរិច្ឆេទចេញសញ្ញាបត្របរិញ្ញាបត្ររបស់ខ្លួន ត្រូវរាប់បញ្ចូលសម្រាប់គណនារយៈពេលនៃបទពិសោធន៍ការងារ។

រយៈពេលនៃបទពិសោធន៍ការងាររបស់អ្នកវិជ្ជាជីវៈ ត្រូវគណនាដោយបូកបញ្ចូលរយៈពេលបំពេញការងារដែលមានចែងក្នុងឯកសារបញ្ជាក់បទពិសោធន៍ការងារទាំងអស់។

ក្នុងករណីអ្នកវិជ្ជាជីវៈបានបំពេញការងារពេញម៉ោង រយៈពេលនៃបទពិសោធន៍ការងារត្រូវគណនាជាឆ្នាំដូចមានចែងក្នុងឯកសារបញ្ជាក់បទពិសោធន៍ការងារ។

ក្នុងករណីអ្នកវិជ្ជាជីវៈបានបំពេញការងារក្រៅម៉ោង រយៈពេលនៃបទពិសោធន៍ការងារត្រូវគិតជាឆ្នាំ ដោយក្នុងរយៈពេល១(មួយ)ឆ្នាំ អ្នកវិជ្ជាជីវៈនោះត្រូវបំពេញការងារឱ្យបានយ៉ាងតិច២០០០(ពីរពាន់)ម៉ោង។

**ប្រការ២.**_

ប្រកាសលេខ ៧៥ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាសនិងក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់ ត្រូវបានធ្វើការកែសម្រួលដោយបន្ថែម ប្រការ៣ ស្ទួន ដូចតទៅ៖

**ប្រការ៣._ស្ទួន**

នាយកបច្ចេកទេសរបស់សហគ្រាសនិងក្រុមហ៊ុនសិក្សាគម្រោងប្លង់ ត្រូវតែជា**ស្ថាបត្យករ គ.ស.ក.** ឬ**វិស្វករអាជីព**។

នាយកបច្ចេកទេសរបស់សហគ្រាសនិងក្រុមហ៊ុនសាងសង់ ត្រូវតែជា**វិស្វករអាជីព**។

នាយកគម្រោងរបស់សហគ្រាសនិងក្រុមហ៊ុនសាងសង់ ត្រូវតែជា**ស្ថាបត្យករ គ.ស.ក.**។

ស្ថាបត្យកររបស់សហគ្រាសនិងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ ត្រូវតែជាស្ថាបត្យករដែលបានចុះបញ្ជីនៅគណៈស្ថាបត្យករកម្ពុជា។

វិស្វកររបស់សហគ្រាសនិងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ ត្រូវតែជាវិស្វករដែលបានចុះបញ្ជីនៅគណៈវិស្វករកម្ពុជា។

## ជំពូកទី២
## អវសានប្បញ្ញត្តិ

**ប្រការ៣.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.**_

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ១៣កើត ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

សាយ សំអាល់

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

**"ដើម្បីជូនជ្រាប"**

- ដូចប្រការ៤ **"ដើម្បីអនុវត្ត"**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ